នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០៤/២/១៩-០៥-២០២០-អវតក-អជតក(០៤) |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 26-May-2020, 13:32
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងលិខិតរបស់ អោ អាន ទាក់ទងនឹងបណ្ដឹងសាទុក្ខជាបន្ទាន់របស់គាត់ប្រឆាំងនឹងការរំលត់ចោលនូវចោទប្រកាន់នៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញាអន្តរជាតិ:**
លោកស្រី Brenda J. HOLLIS

**ចម្លងជូន:**

**សហព្រះរាជអាជ្ញាជាតិ:**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**
ហុង គីមសួន
ឡោ ជុនធី
សំ សុគង់
ស៊ិន សារ៉ន
Emmanuel JACOMY

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម C. N. JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

Martine JACQUIN
Daniel MCLAUGHLIN
Nushin SARKARATI
ជេត វណ្ណលី
គីម ម៉េងឃី

**សហមេធាវីការពារក្ដី អោ អាន:**
មុំ លុជ្ជ
Richard ROGERS
Göran SLUITER

ទី ស្រីនណា
វ៉ែន ពៅ
Laure DESFORGE
Isabelle DURAND
Lyma NGUYEN

## I. សេចក្តីផ្តើម និង ប្រវត្តិ

1. សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") សូមធ្វើការឆ្លើយតបទៅនឹងលិខិតរបស់ អោ អាន ទាក់ទងនឹងបណ្តឹងសាទុក្ខជាបន្ទាន់របស់គាត់ចំពោះការរំលត់ជាធរមាននៃសំណុំរឿង០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង[1]។ សម្រាប់មូលហេតុដូចបានពិភាក្សាខាងក្រោម ស.ព.អ ស្នើសុំថា អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") ច្រានចោលអំណះអំណាងនានាដែលមាននៅក្នុងលិខិតរបស់ អោ អាន និងទទួលយកឧបាស្រ័យដែលបានស្នើសុំនៅក្នុងបណ្តឹងសាទុក្ខរបស់ ស.ព.អ[2]។

## II. ការឆ្លើយតប

2. ជាបញ្ហាបឋម អោ អាន ឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់ ស.ព.អ ក្នុងទម្រង់ជាលិខិតទៅកាន់ អ.ជ.ត.ក ជាជាងជាសារណាផ្លូវការ ដោយអះអាងថាវា "មិនសមស្រប" ក្នុងការអនុវត្តតាមសេចក្តីណែនាំអនុវត្ត ដោយហេតុថា អ.ជ.ត.ក មិនទទួលយកបណ្តឹងរឿងក្តីនេះទេ[3]។ សូម្បីតែភាគីតវ៉ាទៅនឹងយុត្តាធិការបុគ្គល - ដែលទៅឲ្យដល់ចំណុចសំខាន់បំផុតថាតើអង្គជំនុំជម្រះមួយបានទទួល

---

[1] លិខិតពីក្រុមមេធាវីការពារក្តី អោ អាន ផ្ញើជូនចៅក្រមអង្គជំនុំជម្រះតុលាការកំពូល ដោយមានចំណងជើងថា "ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង" ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០ ("លិខិតរបស់ អោ អាន")។ លិខិតរបស់ អោ អាន បានបញ្ជូនតាមសារអេឡិចត្រូនិកទៅកានចៅក្រម អ.ជ.ត.ក និងភាគីនៃសំណុំរឿង ០០៤/២ ជាភាសាអង់គ្លេសនៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០ (*សូមមើល* សារអេឡិចត្រូនិកពី Kristin Rosella មានចំណងជើងថា "លិខិតរបស់ អោ អាន ផ្ញើជូនលោកប្រធាន និងចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល" ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០ ម៉ោង ១១:២៥នាទីព្រឹក (ភ្ជាប់ជាមួយនូវសំណៅជាភាសាអង់គ្លេសនៃលិខិតនេះ)។ សារអេឡិចត្រូនិកពី Kristin Rosella មានចំណងជើងថា "លិខិតរបស់ អោ អាន ផ្ញើជូនលោកប្រធាន និងចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល" ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ ម៉ោង ១០:២៤នាទីព្រឹក (ភ្ជាប់ជាមួយនូវសំណៅជាភាសាអង់គ្លេសនៃលិខិតនេះ))។ *សូមមើលផងដែរ* សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក, អ.វ.ត.ក/០១/២០០៧/វិសោធនកម្មថ្ងៃទី៧ ខែមីនា ឆ្នាំ២០១២ ("សេចក្តីណែនាំអនុវត្ត") មាត្រា ៨.៤, ៨.៥។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មទី៩) ដែលត្រូវបានកែប្រែឡើងវិញនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង" ឬ "វិធាន") វិធាន ៣៩(៣)។ ដោយសារតែ ៥ថ្ងៃ នៃថ្ងៃប្រតិទិនក្រោយការជូនដំណឹងអំពីការបកប្រែត្រូវនឹងថ្ងៃអាទិត្យ ទី២៤ ខែឧសភា ឆ្នាំ២០២០ ហើយថ្ងៃច័ន្ទ ទី២៥ ខែឧសភា ឆ្នាំ២០២០ គឺជាថ្ងៃឈប់សម្រាករបស់ UNAKRT (ថ្ងៃបុណ្យ Eid-al-Fitr) ស.ព.អ ដាក់ចម្លើយតបរបស់គាត់នៅថ្ងៃធ្វើការបន្ទាប់ គឺថ្ងៃអង្គារ ទី២៦ ខែឧសភា ឆ្នាំ២០២០។

[2] ឯកសារ **E004/2/1** បណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០ ("បណ្តឹងសាទុក្ខរបស់ ស.ព.អ") កថាខណ្ឌ ៧៧។

[3] *ដូយពី* លិខិតរបស់ អោ អាន ទំព័រ ១។

បណ្ដឹងយ៉ាងត្រឹមត្រូវ ឬយ៉ាងណា - ក៏ត្រូវគោរពតាមគោលការណ៍ណែនាំរបស់សេចក្ដីណែនាំអនុវត្ត ដែរ[4]។ ជាងនេះទៀត វាគឺជាការងាររបស់អង្គជំនុំជម្រះ - មិនមែនជាការងាររបស់ភាគីទេ - ក្នុងការកំណត់ថាតើខ្លួនបានទទួលបណ្ដឹងយ៉ាងត្រឹមត្រូវ ឬទេ។ ហេតុដូច្នេះ ស.ព.អ ស្នើសុំថា ត្រូវតម្រូវឱ្យ អោ អាន ដាក់ចម្លើយតបរបស់ខ្លួនក្នុងសារណាដែលគោរពតាមសេចក្ដីណែនាំអនុវត្ត។

3. អោ អាន អះអាងដោយគ្មានអង្គសេចក្ដីថា បណ្ដឹងសាទុក្ខរបស់ ស.ព.អ មិនមែនជាបណ្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ") ដែលបានរំលត់កិច្ចដំណើរការនីតិវិធីជាធរមាននោះទេ[5]។ បណ្ដឹងសាទុក្ខរបស់ ស.ព.អ បង្ហាញថា *ការបញ្ឈប់*ទាំងអស់នៃកិច្ចតាមផ្លូវតុលាការដាច់ខាតជាផ្លូវការបង្កើតបានជាសេចក្ដីសម្រេច[6] ដែលត្រូវបានបំពេញដោយការរួមផ្សំបញ្ចូលគ្នានៃ (i) ភាពនៅស្ងៀមរបស់ អ.ជ.ស.ដ (ii) សេចក្ដីថ្លែងការចុះថ្ងៃទី៣ ខែមេសា ដែលបញ្ជាក់ច្បាស់ថាការនៅស្ងៀមនឹងបន្តទៅមុខទៀត និង (iii) ការបង្វិលជារូបវន្តនៃសារណានានាមកកាន់ភាគីវិញ[7]។ រួមបញ្ចូលគ្នា សកម្មភាពទាំងនេះបានច្រានចោលបញ្ហាច្បាប់នានានៅចំពោះមុខ អ.ជ.ស.ដ ទាំងស្រុង ដោយមិនបន្សល់ទុកនូវការសង្ស័យណាថា អ.ជ.ស.ដ នឹងមិនអនុវត្តយុត្តាធិការដើម្បីស្វែងយល់អំពីសារណាក្នុងសំណុំរឿង០០៤/២ ទេ កុំថាឡើងដោះស្រាយវានោះ[8]។

---

[4] *សូមមើល ឧទាហរណ៍* ឯកសារ **D251** សំណើសុំដាក់សារណាថាតើ អ៊ឹម ចែម គួរត្រូវបានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់" និង/ឬស្ថិតក្នុងចំ ណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ EN 01120934 (បានកត់សម្គាល់មាត្រា ៥.១ នៃសេចក្ដីណែនាំអនុវត្ត) កថាខណ្ឌ៩ (ដោយបានកំណត់ចំនួនទំព័រសម្រាប់ភាគីឱ្យអនុវត្តតាមស្រប ទៅនឹងសេចក្ដីណែនាំអនុវត្ត នៅពេលដែលធ្វើសារណារបស់ខ្លួន)។ ឯកសារ **D251/4** សេចក្ដីសង្កេតរបស់អ្នកស្រី អ៊ឹម ចែម ស្ដីពីបញ្ហាថាតើអ្នកស្រីគួរត្រូវបានចាត់ទុកជា "មេដឹកនាំជាន់ខ្ពស់" ឬ បុគ្គលម្នាក់ស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥ កថាខណ្ឌ៣, ៨, ៦០។ ឯកសារ **D251/6** សេចក្ដីសង្កេតរបស់សហព្រះរាជអាជ្ញាជាតិអំពីការអនុវត្តឆន្ទានុសិទ្ធិរបស់ ស.ច.ស លើករណី អ៊ឹម ចែម យោងតាមឯកសារលេខ D251 ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥ កថាខណ្ឌ ១៣។

[5] លិខិតរបស់ អោ អាន ទំព័រ ២-៣។

[6] សំណុំរឿង០០២-ឯកសារ **E176/2/1/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ("សេចក្ដីសម្រេចតាមវិធាន ៣៥") កថាខណ្ឌ ២៥។

[7] ឯកសារ **E004/2/1** បណ្ដឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ៤១-៤៤។ *សូមមើលផងដែរ* ឯកសារ **E004/2/1.1.16** សេចក្ដីថ្លែងការណ៍របស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង នៃ អ.វ.ត.ក ទាក់ទងនឹងសំណុំរឿង ០០៤/២ ពាក់ព័ន្ធនឹង អោ អាន ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ ("សេចក្ដីថ្លែងការណ៍ថ្ងៃទី៣ ខែមេសា") ទំព័រ ២។

[8] *ផ្ទុយពី* លិខិតរបស់ អោ អាន ទំព័រ ៣។

ការបង្វិលត្រឡប់របស់ អ.ជ.ស.ដ នៃឯកសារនានាមកភាគីវិញបង្កើតបានជា "ផ្នែកប្រតិបត្តិ" នៃសេចក្ដីសម្រេច ខណៈដែលសេចក្ដីថ្លែងការចុះថ្ងៃទី៣ ខែមេសា បានផ្ដល់សេចក្ដីសង្ខេបជាលាយលក្ខណ៍អក្សរនៃទស្សនៈខ្វែងគ្នារបស់ចៅក្រម និងមូលហេតុដែលពួកគាត់មិនព្រមបំពេញកិច្ច[9]។ អោ អាន ខ្លួនគាត់ផ្ទាល់បានកត់សម្គាល់ថា ចៅក្រម អ.ជ.ស.ដ បានថ្លែងថា ពួកគេបានផ្ដល់សេចក្ដីថ្លែងការណ៍សម្រាប់ "តម្លាភាព និងភាពច្បាស់លាស់" ដែលជាផ្នែកមួយផ្សេងទៀតនៃ*ការពញ្ញាក់*[10]។

4. ផ្ទុយទៅនឹងការបង្ហាញរបស់ អោ អាន អំពីបណ្ដឹងសាទុក្ខរបស់ ស.ព.អ សហព្រះរាជអាជ្ញាអន្តរជាតិមិនមែនកំពុងប្ដឹងសាទុក្ខសេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ ("អ.ប.ជ") ដោយមិនត្រូវបានអនុញ្ញាតនោះទេ[11]។ ផ្ទុយទៅវិញ ស.ព.អ កំពុងស្នើសុំឲ្យ អ.ជ.ត.ក ធានាថា វិធានការរដ្ឋបាលដែលជាលទ្ធផលចេញពីការបរាជ័យរបស់ អ.ប.ជ ក្នុងការឈានទៅដល់សំឡេងភាគច្រើនលើសលុបត្រូវបានអនុវត្ត ដូចដែលត្រូវបានតម្រូវដោយច្បាប់។ ដូចដែលបានរៀបរាប់នៅក្នុងបណ្ដឹងសាទុក្ខរបស់ ស.ព.អ ប្រសិនបើ អ.ប.ជ មិនបានបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយសំឡេងភាគច្រើនលើសលុបទេនោះ រឿងក្ដីនេះត្រូវប្ដឹងទៅ អ.ជ.ស.ដ ដោយផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយសំណុំរឿងត្រូវបន្តដំណើរការទៅជំនុំជម្រះ អនុលោមតាមវិធាន ៧៧(១៣)(ខ), ៧៩(១), ១(២), *វិធានពិសេស* និងគោលការណ៍ស្វ័យប្រវត្តិ ដែលត្រូវបានចែងនៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក[12]។ បណ្ដឹងសាទុក្ខរបស់ ស.ព.អ បង្ហាញថា អ.ប.ជ បានឈានដល់ការជាប់គាំងលើ*ផលវិបាកផ្នែករដ្ឋបាល*នៃសេចក្ដីពិចារណារបស់ខ្លួន ដែលរួមបញ្ចូលទាំងសេចក្ដីជូនដំណឹងអំពីសេចក្ដីពិចារណារបស់ខ្លួន និងការបញ្ជូនសំណុំរឿងទៅកាន់ អ.ជ.ស.ដ[13]។ វាក៏បង្ហាញផងដែរថា អ.ជ.ស.ដ មិនបានដោះស្រាយការជាប់គាំងនោះទេ ដែលហេតុដូច្នេះបានរំលត់កិច្ចដំណើរការនីតិវិធីជាធរមាន និងបានធ្វើឲ្យខូចប្រយោជន៍ដល់ភាគីក្នុងសំណុំរឿង០០៤/២[14]។ ទោះបីជាការអះអាងរបស់ អោ អាន ដែលថា "ពុំមាននៅសេសសល់នូវ

---

[9] សំណុំរឿង០០២-ឯកសារ **E176/2/1/4** សេចក្ដីសម្រេចតាមវិធាន ៣៥ កថាខណ្ឌ ២៥។ ឯកសារ **E004/2/1.1.16** សេចក្ដីថ្លែងការណ៍ថ្ងៃទី៣ ខែមេសា ទំព័រ ២។ *ផ្ទុយពី* លិខិតរបស់ អោ អាន ទំព័រ ៣។

[10] សំណុំរឿង ០០២-ឯកសារ **E176/2/1/4** សេចក្ដីសម្រេចតាមវិធាន ៣៥ កថាខណ្ឌ ២៥។ លិខិតរបស់ អោ អាន ទំព័រ ៣។

[11] លិខិតរបស់ អោ អាន ទំព័រ ២, ៣, ៥។

[12] ឯកសារ **E004/2/1** បណ្ដឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ៥០-៥៧។

[13] ឯកសារ **E004/2/1** បណ្ដឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ១៥-១៨, ២៤-២៥។

[14] ឯកសារ **E004/2/1** បណ្ដឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ២-៣, ១២, ២១-២២, ២៧-៣០, ៤៣-៤៤, ៤៨-៤៩, ៥៨-៦១, ៦៧-៦៨, ៧០-៧២, ៧៥។

"ការរាំងស្ទះផ្នែកច្បាប់ ឬឧបសគ្គផ្នែកអនុវត្ត" ឬ "ចន្លោះប្រហោងដែលអាចមាននៅក្នុងកិច្ចដំណើរការនីតិវិធីច្បាប់" ដែលអង្គជំនុំជម្រះតុលាការកំពូលត្រូវដោះស្រាយ"[15] ក៏ដោយ ក៏ការទទួលស្គាល់របស់គាត់អំពី "កត្តារាំងស្ទះបច្ចុប្បន្ន"[16] បញ្ជាក់យ៉ាងច្បាស់អំពីការដឹងឮរបស់គាត់អំពីភាពជាប់គាំងដែលមិនអាចត្រូវបានដោះស្រាយដោយគ្មានអន្តរាគមន៍ពី អ.ជ.ត.ក ឡើយ។

5. ខ្លឹមសារភាគច្រើនក្នុងលិខិតរបស់ អោ អាន ដែលជំទាស់ទៅនឹងបណ្តឹងសាទុក្ខរបស់ ស.ព.អ គឺផ្អែកលើកំហុសថា សេចក្តីពិចារណារបស់ អ.ប.ជ បានរំលត់កិច្ចដំណើរការនីតិវិធី នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២០[17]។ ដើម្បីគាំទ្រដល់ការតវ៉ារបស់ខ្លួននេះ អោ អាន ជំទាស់ថា សំឡេងភាគច្រើនធម្មតាគម្បីមានអាទិភាពលុបលើវិធាននៃសំឡេងភាគច្រើនលើសលុប និងគោលការស្វ័យប្រវត្តិដែលជាមជ្ឈត្តិកនៃក្របខណ្ឌច្បាប់របស់ អ.វ.ត.ក[18]។ គាត់ក៏យល់ច្រឡំផងដែរចំពោះការប្រើប្រាស់ឲ្យបានត្រឹមត្រូវនូវគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដែលពាក់ព័ន្ធជាបឋមនឹងវិមតិសង្ស័យ *នៅឯសវនាការជំនុំជម្រះ* និងមិនអនុវត្តចំពោះបញ្ហានៃការបកស្រាយច្បាប់នៅទីនេះទេ[19]។ ជាចុងក្រោយ ការអះអាងរបស់គាត់ គឺយល់ខុសចំពោះមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា[20]។ ស.ព.អ បានឆ្លើយតបលម្អិតជាច្រើនលើកច្រើនសារទៅនឹងអំណះអំណាងទាំងនេះ ដូច្នេះ ស.ព.អ សូមបង្រួមចម្លើយតបទាំងនោះតាមរយៈសេចក្តីយោង[21]។

---

[15] លិខិតរបស់ អោ អាន ទំព័រ៤។

[16] លិខិតរបស់ អោ អាន ទំព័រ ១, ៤។

[17] លិខិតរបស់ អោ អាន ទំព័រ ៣, ៤, ៥, ៧។

[18] លិខិតរបស់ អោ អាន ទំព័រ ៥, ៦, ៧។

[19] លិខិតរបស់ អោ អាន ទំព័រ ៥។

[20] លិខិតរបស់ អោ អាន ទំព័រ ៦។

[21] *សូមមើល ជាឧទាហរណ៍* ឯកសារ **D359/28 & D360/37** ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយតបរបស់ អោ អាន ទៅនឹងសំណើរបស់ ស.ព.អ សុំឲ្យចាត់វិធានការចាំបាច់ទាំងអស់ដើម្បីបញ្ជូន សំណុំរឿង ០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០ កថាខណ្ឌ៤ (អំពី អំណះអំណាងសំឡេងភាគច្រើន) កថាខណ្ឌ ៦-៨ (អំពី *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ)* កថាខណ្ឌ ៩ (អំពី មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា)។ ឯកសារ **D359/30 & D360/39** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ អោ អាន សុំឲ្យចាត់វិធានការចាំបាច់ទាំងអស់ដើម្បីបញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០២០, កថាខណ្ឌ ១២-១៤ (អំពី អំណះអំណាងសំឡេងភាគច្រើន) កថាខណ្ឌ ១៦ (អំពី *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ)*។ ឯកសារ **D363/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ អោ អាន សុំឲ្យបញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ (ជាមួយឧបសម្ព័ន្ធសម្ងាត់ A1-K2) ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០ ("ចម្លើយតបរបស់ ស.ព.អ ទៅនឹងសំណើសុំឲ្យ

6. អោ អាន អះអាងថា មាន "ការង្គាញ" ថា ស.ព.អ "លុបបំបាត់ចោល" នូវសំណើរបស់ អោ អាន ដាក់ជូនសហចៅក្រមស៊ើបអង្កេតឲ្យដាក់បញ្ចូលសំណុំរឿងទុកក្នុងបណ្ណសារ[22]។ ការអះអាងនេះ គឺគ្មានអង្គសេចក្តីទាល់តែសោះ ដោយសារ ស.ព.អ អត់បានដឹងថា មានសំណើរបស់ អោ អាន ទេ រហូតដល់ពេលលោកស្រីត្រូវបានជូនដំណឹង ដែលមានរយៈពេលជាងពីរម៉ោងក្រោយពេលគាត់ បាន ដាក់បណ្តឹងសាទុក្ខរបស់ខ្លួន[23]។ ទោះបីជាលោកស្រី *បាន* ដឹងអំពីសំណើនេះក្តី ក៏វាគ្មានបន្ទុកអ្វីទៅ លើបណ្តឹងសាទុក្ខរបស់ ស.ព.អ ដែរ។ និយាយដោយខ្លី សំណើនោះបានចោទប្រកាន់ទាំងខុសថា គ្មានបទប្បញ្ញត្តិស្តីពីកាលៈទេសៈនៃរឿងក្តីនេះទេ ហើយវិធាន ៦៩(២)(ខ) គប្បីអនុវត្ត *ក្នុងករណី សមស្រប* ដោយគាត់ធ្វើមិនដឹងមិនឮចំពោះវិធាន ៧៧(១៣)(ខ) និងគោលជំហរស្ម័យប្រវត្តិ ជាមូលដ្ឋាន និងជាកត្តាកំណត់ដែលប្បញ្ញត្តិអំពីវិបាកនានាដែលត្រូវតែអនុវត្តតាម នៅពេលណា សំឡេងភាគច្រើនលើសលុបមិនអាចរកបានដើម្បីបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ[24]។

7. ជាចុងក្រោយ អោ អាន ព្យាយាមអូសទាញ អ.ជ.ត.ក ឲ្យងាកចេញពីបញ្ហាស្នូលនៃបណ្តឹងសាទុក្ខ របស់ ស.ព.អ តាមរយៈការលាបពណ៌នៃសេចក្តីយោងរបស់ ស.ព.អ ទៅនឹងកាតព្វកិច្ចតុលាការ និងក្រមសីលធម៌ក្នុងន័យមិនល្អ ដោយបាននិយាយសំដៅដល់សេចក្តីយោងទាំងនោះថាជា "ការបង្កប់ ន័យ" ថា អ.ជ.ស.ជ មានកង្វះខាតនូវឯករាជ្យភាព និងអនាគតិ[25]។ ដើម្បីឲ្យច្បាស់ បណ្តឹងសាទុក្ខ របស់ ស.ព.អ គឺផ្អែកលើការបរាជ័យរបស់ អ.ជ.ស.ជ ក្នុងការអនុវត្តកាតព្វកិច្ចតុលាការរបស់ខ្លួន ស្របតាមក្របខណ្ឌច្បាប់របស់ អ.វ.ត.ក ដែលតម្រូវឲ្យ អ.ជ.ស.ជ បំពេញទៅតាមគោលជំហរ ស្ម័ប្រវត្តិជាមូលដ្ឋាន និងជាកត្តាកំណត់ដែលបានប្តឹងឲ្យខ្លួនទទួលយកនូវសំណុំរឿង ០០៤/២។ ការ

---

បញ្ចូលទៅក្នុងបណ្ណសារ") កថាខណ្ឌ ១១-១២ (អំពី អំណះអំណាងសំឡេងភាគច្រើន) កថាខណ្ឌ ១៤-១៦ (អំពី *វិមតិសង្ស័យ បានជាប្រយោជន៍ដល់ជនជាប់ចោទ)* កថាខណ្ឌ ១៧ (អំពី មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា)។ ឯកសារ **E004/2/1.2.26** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសេចក្តីសង្ខេបនៃអញ្ញត្រកម្មរបស់ អោ អាន អនុលោមតាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ កថាខណ្ឌ ១២-១៥ (អំពី *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ)*។

[22] លិខិតរបស់ អោ អាន ទំព័រ ៦។ *សូមមើលផងដែរ* ទំព័រ ៥។

[23] សារអេឡិចត្រូនិកនៃសេចក្តីជូនដំណឹង ពីមន្ត្រីទទួលបន្ទុកសំណុំរឿង ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០, វេលាម៉ោង ១:២២ រសៀល (ជូនដំណឹងអំពីឯកសារ **D363** សំណើ [របស់ អោ អាន] សុំឲ្យបញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ។ ឯកសារ **E004/2/1** បណ្តឹងសាទុក្ខរបស់ ស.ព.អ ទំព័រមុខ (កត់សំគាល់ថា បណ្តឹងសាទុក្ខបានដាក់នៅថ្ងៃទី៤ ខែ ឧសភា ឆ្នាំ ២០២០ វេលាម៉ោង ១១:០០ ព្រឹក)។

[24] *សូមមើល* លិខិតរបស់ អោ អាន ទំព័រ ៦។ ឯកសារ **D363/1** ចម្លើយតបរបស់ ស.ព.អ ទៅនឹងសំណើសុំឲ្យបញ្ចូល ទៅក្នុងបណ្ណសារ កថាខណ្ឌ ១១។

[25] លិខិតរបស់ អោ អាន ទំព័រ ១, ៤, ៦។

ខកខាននេះបានបង្ហាញយ៉ាងច្បាស់តាមរយៈភាពនៅស្ងៀមរបស់ អ.ជ.ស.ដ ក្នុងការធ្វើឲ្យរឿងក្ដីនេះដំណើរការទៅមុខ និងសេចក្ដីថ្លែងការណ៍ចុះថ្ងៃទី៣ ខែមេសា និងការបង្វិលសារណារបស់ភាគីត្រឡប់មកម្ចាស់ដើមវិញ ដែលបានបញ្ជាក់អំពីការបដិសេធរបស់អង្គជំនុំជម្រះ ក្នុងការប្រកាសអំពីបញ្ហាត្រឹមត្រូវតាមច្បាប់នៅចំពោះមុខខ្លួន។ បណ្ដឹងសាទុក្ខរបស់ ស.ព.អ បានពឹងផ្អែកលើច្បាប់មិនមែនជៀមដាម ឬបញ្ឆិតបញ្ឆៀង ទោះបីជាមានការព្យាយាមជាក់ស្ដែងរបស់ អោ អាន ដើម្បីចាត់ថ្នាក់វាផ្សេងពីនេះក៏ដោយ។

## III. ឧបាស្រ័យដែលស្នើឡើង

8. អាស្រ័យមូលហេតុដូចបានជម្រាបជូនខាងលើ ស.ព.អ សូមស្នើឲ្យ អ.ជ.ត.ក ៖

(i) ច្រានចោលអំណះអំណាងដែលមាននៅក្នុងលិខិតរបស់ អោ អាន ដោយឈរលើទឡ្ហីករណ៍ថា អំណះអំណាងទាំងនោះគ្មានអង្គសេចក្ដី។

(ii) បង្គាប់ឲ្យ អោ អាន ដាក់ចម្លើយតបដែលមាននៅក្នុងលិខិតរបស់គាត់ជាសារណា ស្របតាមសេចក្ដីណែនាំអនុវត្ត, ហើយនិង

(iii) ផ្ដល់ឧបាស្រ័យតាមសំណើសុំ ដូចមានរៀបរាប់នៅក្នុងបណ្ដឹងសាទុក្ខរបស់ ស.ព.អ[26]៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០ | **លោកស្រី Brenda J HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |

[26] ឯកសារ **E004/2/1** បណ្ដឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ៧៧។